# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ៖**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ឧសភា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

### I.សេចក្តីផ្តើម ៖

នៅខែឧសភានេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្នារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែង ដូចខាងក្រោម ៖

### II.ការងារកែទម្រង់ច្បាប់ និងតុលាការ ៖

- បន្តការពិនិត្យលើរបាយការណ៍ស្តីពីការសិក្សាអំពីយន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការដោយ UNDP
- ប្រជុំជាមួយអ្នកជំនាញការ DIHR ( Danish Institute for Human Rights ) ដើម្បីពិភាក្សា និងពិគ្រោះ យោបល់ផ្នែកបច្ចេកទេសចំពោះការធ្វើបញ្ជីគម្រោង ( Project Catalogue )
- ប្រជុំផ្ទៃក្នុងដើម្បីជម្រុញឱ្យការងាររបស់ក្រុមគម្រោងមានដំណើរការល្អទៅមុខ
- ប្រជុំក្រុមការងាបច្ចេកទេស ( Technical Working Group )
- រៀបចំកែសម្រួលកម្មវិធីសកម្មភាពតាមស្មារតីរបស់អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៥ ។

### III. ការស្រាវជ្រាវ ៖

- តាមដានប្រមូលផ្តុំគំនិត និងស្រាវជ្រាវឯកសារផ្សេងៗដែលទាក់ទងនឹងការផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង
- រៀបចំ និងចងក្រងឯកសារផ្សេងៗដែលចាំបាច់ក្នុងការរៀបចំគម្រោង ។

## IV. ផ្សេងៗ ៖

- បានចូលរួមប្រជុំអន្តរក្រសួង
- បានអញ្ជើញគណៈកម្មការយូនីកូដ ( Unicode ) មកធ្វើបទឧទ្ទេសនាមអំពីការប្រើប្រាស់អក្ខរក្រមខ្មែរក្នុងកុំព្យូទ័រ ( Unicode )
- បានចូលរួមសិក្ខាសាលាអំពីសេរីភាពទទួលបានសារព័ត៌មាន
- ចូលរួមប្រជុំប្រចាំសប្តាហ៍របស់ក្រុមការងារធ្វើវិសោធនកម្មច្បាប់ការងារជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

## V. សេចក្តីសន្និដ្ឋាន

នៅក្នុងខែឧសភាឆ្នាំ២០០៥នេះ អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌បានបំពេញការងាររបស់ខ្លួនទៅតាមទិសដៅគ្រោងទុក ដោយបានបញ្ចប់នូវការកែសម្រួលឯកសារកម្មវិធី សកម្មភាពទៅតាមស្មារតីបន្តប្រជុំគណៈរដ្ឋមន្ត្រី និងត្រៀមដាក់ជូនអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ពិនិត្យ សម្រេច ។

## VI. ទិសដៅសម្រាប់អនុវត្តក្នុងខែបន្ត

- បន្តការងាររៀបចំបញ្ចើគម្រោង
- បញ្ចប់ការពិនិត្យលើរបាយការណ៍ស្តីពីការសិក្សាអំពីយន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការដោយ UNDP និងរៀបចំសិក្ខាសាលាវាយតម្លៃចុងក្រោយលើរបាយការណ៍នេះ
- រៀបចំការប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ពិនិត្យកម្មវិធីសកម្មភាពកែសម្រួលតាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៥*

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

ប្រធាន អ.គ.គ

សេង វ៉ាន់ដា

ស៊ុយ ម៉ុងលាង